**Declassified to Public**
**05 May 2021**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jul-2016, 10:57
CMS/CFO: Sann Rada

# ដីកាសម្រេចទី ២ លើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹង ធនធានបន្ថែមរបស់មេធាវីការពារក្តី

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តីអោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តីយឹម ទិត្យ**
សូ មូស្សេន្នី
Suzana TOMANOVIĆ

**អង្គភាពគាំពារការការពារក្តី**
Issac ENDELEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គភាពធនធានមនុស្ស**
Hamayoon MUBTAKIR

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្ដី យឹម ទិត្យ ("មេធាវីការពារក្ដី") បានស្នើ ស.ច.ស បង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដី ("អ.គ.ក") ត្រូវ៖

ក. បញ្ជាក់ថា មេធាវីការពារក្ដី យ៉ាងហោចណាស់ អាចរៀបចំរឿងក្ដីរបស់ខ្លួន តាមថវិកាដែលបានជូនដំណឹងពីដើម គឺ ២១០ ០០០ ដុល្លារ។

ខ. ផ្ដល់កិច្ចសន្យាការងារភ្លាមៗជូនដល់លោក Newille Sorab ជាអ្នកប្រឹក្សាជំនាញមិនយកប្រាក់កម្រៃសម្រាប់រយៈពេលរហូតដល់ពេលដែលគាត់ត្រូវបានចាត់តាំងជាសហមេធាវីការពារក្ដីអន្តរជាតិ។

គ. ពិចារណាថា ពាក្យសុំរបស់លោក Sorab ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ត្រូវដាក់ចូលក្នុងបញ្ជីឈ្មោះមេធាវីបរទេសរបស់ អ.គ.ក យោងតាមវិធាន ១២ (២)(ឃ)(ii) ("ពាក្យសុំ ខែ មេសា ឆ្នាំ ២០១៦")[1]។

៣. នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចដែលខ្ញុំបានបដិសេធចំណុច គ នៃសំណើរបស់មេធាវីការពារក្ដី("ដីកាសម្រេចទី១")[2]។ នៅក្នុងដីកាសម្រេចទី១ ខ្ញុំបានជូនដំណឹងមេធាវីការពារក្ដី ថា ដើម្បីសម្រេចលើចំណុច ក រាប់បញ្ចូលទាំងថាតើខ្ញុំមានយុត្តាធិការសម្រេចលើសំណើឬអត់នោះ ខ្ញុំចាំបាច់ត្រូវដឹងពី៖

---

[1]សំណុំរឿង 004 ឯកសារ D312 *សំណើបន្ទាន់របស់ យឹម ទិត្យ សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្ដី ផ្ដល់ជូនមេធាវីការពារក្ដី យឹម ទិត្យ នូវធនធានដែលខ្លួនត្រូវទទួលបានតាមថវិកាដើម* ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៦("សំណើ") ទំព័រ ១៥ [អង់គ្លេស]។

[2]សំណុំរឿង 004 ឯកសារ D312/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានរបស់មេធាវីការពារក្ដី* ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ២០-២១ និង ២៥។

ក. កាលបរិច្ឆេទ និងរបៀបដែលមេធាវីការពារក្តី បានទទួលព័ត៌មានពី អ.គ.ក ថា ថវិការបស់ខ្លួនមានចំនួន ២១០ ០០០ ដុល្លារ និង

ខ. កាលបរិច្ឆេទ ដែល អ.គ.ក បានដឹងថា តាមពិត ថវិកាដែលមានពិតប្រាកដគឺត្រឹមតែ ១៨០ ០០០ ដុល្លារតែប៉ុណ្ណោះ[3]។

៤. ចំពោះចំណុច ខ នៃសំណើរបស់មេធាវីការពារក្តី ខ្ញុំបានផ្តល់មតិយោបល់ជាបឋមអំពីបញ្ហានេះ ប៉ុន្តែ ខ្ញុំមិនបានសម្រេចលើបញ្ហានេះឡើយ ពីព្រោះថា ខ្ញុំបានសម្រេចផ្តល់ឱកាសជូនទៅប្រធានធនធានមនុស្ស ឲ្យដាក់សារណាលើបញ្ហានានាដែលពាក់ព័ន្ធនឹងចំណុច ខ ប្រសិនបើគាត់មានបំណងដូច្នេះ[4]។ ខ្ញុំនៅតែទទួលពិនិត្យសំណើរបស់មេធាវីការពារក្តី[5]។

៥. នៅថ្ងៃទី ០៩ និង ១០ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តី និង អ.គ.ក បានដាក់សារណារៀងៗខ្លួនតាមសំណើរបស់ខ្ញុំ ទាក់ទងនឹងចំណុច ក នៃសំណើរបស់មេធាវីការពារក្តី ("សារណារបស់ អ.គ.ក" និង "សារណារបស់មេធាវីការពារក្តី")[6]។

## II. ពិភាក្សា

### ក. សំណើសុំបញ្ជាក់ថា ថវិការបស់មេធាវីការពារក្តី មានចំនួន ២១០ ០០០ ដុល្លារ

៦. នៅកថាខណ្ឌ ៧ នៃសំណើរបស់ អ.គ.ក ប្រធាន អ.គ.ក បញ្ជាក់ថា កម្រិតថវិកា ២១០ ០០០ ដុល្លារសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ នឹងរក្សានៅដដែលនៅឆ្នាំ ២០១៦។ ហេតុនេះ ខ្ញុំយល់ឃើញថា ចំណុច ក នៃសំណើរបស់មេធាវីការពារក្តី លែងមានសុពលភាពហើយ។

### ខ. សំណើសុំផ្តល់កិច្ចសន្យាការងារជូនដល់លោក Newille Sorab ជាអ្នកប្រឹក្សាជំនាញមិនយកប្រាក់កម្រៃ

---

[3] ដីកាសម្រេចទី ១ កថាខណ្ឌ ៣ និង ២៣។

[4] ដីកាសម្រេចទី ១ កថាខណ្ឌ ១៧។

[5] ដីកាសម្រេចទី ១ កថាខណ្ឌ ២៣-២៦។

[6] សំណុំរឿង ០០៤ ឯកសារD312/2 *ផ្តល់ជូនពត៌មានបន្ថែមយោងតាម D312/1* ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦។ សំណុំរឿង ០០៤ ឯកសារD312/3 *របាយការណ៍របស់ អ.គ.ក ផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្តីពីសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានរបស់មេធាវីការពារក្តី* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៦។

៧. ដោយពិនិត្យមើលកថាខណ្ឌ ១១ ដល់ ១២ នៃសារណារបស់ អ.គ.ក ខ្ញុំយល់ឃើញថា ចំណុច ខ នៃសំណើរបស់មេធាវីការពារក្តី ក៏លែងមានសុពលភាពដែរ។

៨. ហេតុនេះ ខ្ញុំជូនដំណឹង អ.គ.ក ថា ខ្ញុំឯកភាពអនុញ្ញាតឲ្យលោក Newille Sorab ចូលពិនិត្យមើលសំណុំរឿង ០០៤ តាមរយៈ Zylab ក្នុងកម្រិតដូចគ្នានឹងការអនុញ្ញាតឲ្យអ្នកប្រឹក្សាច្បាប់ផ្សេងទៀតដែលធ្វើការឲ្យមេធាវីការពារក្តីដែរ និងដរាបណាសហមេធាវីស្នើសុំ។ ប៉ុន្តែ មុនពេលអនុញ្ញាតនេះ លោក Sorab ត្រូវចុះហត្ថលេខាលើកិច្ចសន្យារក្សាការសម្ងាត់ និងកិច្ចសន្យាណាផ្សេងទៀតដែលអ្នកប្រឹក្សាច្បាប់មេធាវីការពារក្តី ធម្មតាត្រូវចុះហត្ថលេខា។

៩. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១០. **ប្រកាស** ថា ចំណុច ក និង ខ នៃសំណើរបស់មេធាវីការពារក្តី លែងមានសុពលភាព។

១១. **ជូនដំណឹង** អ.គ.ក ថា ខ្ញុំឯកភាពឲ្យលោក Sorab ចូលពិនិត្យមើលសំណុំរឿង ០០៤ តាមរយៈ Zylab ដរាបណា លោក Sorab បានចុះហត្ថលេខាលើកិច្ចសន្យាពាក់ព័ន្ធទាំងអស់មុនពេលអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**